# តួនាទីអ្នកសារព័ត៌មាន ដើម្បីកសាងសន្តិភាព

*វគ្គបណ្តុះបណ្តាលសំរាប់អាជីពសារព័ត៌មានដើម្បីសន្តិភាព*

**សេចក្តីអធិប្បាយពីវគ្គបណ្តុះបណ្តាល**

## សេចក្តីសង្ខេបវគ្គសិក្សា

**តួនាទីអ្នកសារព័ត៌មានដើម្បីកសាងសន្តិភាព** គឺជាកម្មវិធីស្នូលមួយ របស់កម្មវិធីបណ្តុះបណ្តាលការកសាងសន្តិភាព នៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៏កម្ពុជា ។ កម្មវិធីសិក្សានេះបង្កើតឡើងដើម្បីឆ្លើយតបទៅនឹងតំរូវការជាក់ស្តែងនៃអ្នកសាព័ត៌មាន និងសមាគមអ្នកសារព័ត៌មានកម្ពុជា ក្នុងគោលបំណងពង្រឹងសមត្ថភាពជូនអ្នកសារព័ត៌មាននូវចំណេះដឹង ជំនាញនៃការកសាងសន្តិភាព និងការការពារទំនាស់ ដែលអាចបញ្ចូលនូវទស្សនៈ និង ឧបករណ៏ជាក់ស្តែងនៃការអប់រំសន្តិភាព វប្បធម៌សន្តិភាព និងវិធីសាស្រ្តអហិង្សានៅក្នុងវិស័យសារព័ត៌មាន។ កម្មវិធីនេះ តំរូវអោយមានការចូលរួមពេញលេញនៅក្នុងវគ្គសិក្ខាសាលាដែលមានរយៈពេល៥ថ្ងៃ។ វគ្គសិក្សានឹងត្រូវធ្វើឡើងជាភាសាខ្មែរ នៅវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៏កម្ពុជា។

*តួនាទីអ្នកសារព័ត៌មានដើម្បីកសាងសន្តិភាព* បានកើតចេញមកអំពីវគ្គសិក្សា *ការងារកសាងសន្តិភាព* នៃកម្មវិធីបណ្តុះបណ្តាលការកសាងសន្តិភាព និងការគ្រប់គ្រងទំនាស់ដែលផ្តល់ដោយកម្មវិធីបណ្តុះបណ្តាលការកសាងសន្តិភាព តាមរយៈការប្រមូលព័ត៌មានពីតំរូវការបណ្តុះបណ្តាលនៃប្រព័ន្ធផ្សព្វផ្សាយ និងការពិភាក្សាជាមួយ និពន្ធនាយក ចាងហ្វាង អ្នកសារព័ត៌មាន និងអ្នកដឹកនាំ សមាគមន៏អ្នកសារព័ត៌មាននៅភ្នំពេញ។ វគ្គសិក្សានឹងផ្តល់នូវទស្សនៈនៃសន្តិភាព ការយល់ដឹងពីទំនាស់ និងជំនាញនៃការវិភាគ និងដោះស្រាយទំនាស់។ កម្មវិធីសិក្សានេះ អ្នកជំនាញបណ្តុះបណ្តាលនៃវិទ្យាស្ថាន CDRI នឹងប្រើករណីសិក្សា និងលើកឡើងនូវរឿងរ៉ាវថ្មីៗក្នុង ប្រទេសកម្ពុជា។ វគ្គសិក្សានេះនឹងសម្របសម្រួលដោយក្រុមអ្នកសម្របសម្រួលរបស់វិទ្យាស្ថាន អ្នកអនុវត្តជាក់ស្តែង និងអ្នកជំនាញឯកទេស កម្ពុជាមកពីខាងក្រៅវិទ្យាស្ថាន CDRI ។

វគ្គបណ្តុះបណ្តាលនេះនឹងពិនិត្យពិចារណាលើទ្រឹស្តី និងការអនុវត្តន៏ជាក់ស្តែងនៅពេលបច្ចុប្បន្ន ដូចដែលគេអនុវត្តលើការដោះស្រាយទំនាស់ដែលកំពុងកើតមានឡើងនៅក្នុងប្រទេសកម្ពុជា និងការអភិវឌ្ឍន៏សមត្ថភាពវិជ្ជាជីវសារព័ត៌មាន និងស្ថាបន័របស់អ្នកសារព័ត៌មាន។ គោលបំណងនៃវគ្គបណ្តុះបណ្តាលនេះគឺ ដើម្បីបង្កើនដល់អ្នកសារព័ត៌មាននូវជំនាញវិជ្ជាជីវនៃការការពារទំនាស់ និងការកសាងសន្តិភាព។ ជំនាញដែលទទួលបានពីវគ្គសិក្សានេះ នឹងជួយសម្របសម្រួលអោយពួកគេ អាចដោះស្រាយទំនាស់ និងបញ្ហាសង្គមមួយចំនួនដែលបាននឹងកំពុងកើតឡើងនៅក្នុងសារព័ត៌មាន/ប្រពន្ធ័ផ្សព្វផ្សាយបច្ចុប្បន្ន ដែលពាក់ពន្ធ័ទៅនឹងបញ្ហារសើប។ ដូច្នេះ វគ្គសិក្សានេះ ជាការកសាងសមត្ថភាពមួយសំរាប់អ្នកសារព័ត៌មាន/ប្រពន្ធ័ផ្សព្វផ្សាយអាចចុះផ្សាយព័ត៌មានបានត្រឹមត្រូវទៅដល់សាធារណជន ហើយវាអាចជាយន្តការមួយ ដើម្បីកាត់បន្ថយភាពតានតឹងតាមរយៈការកសាងទំនុកចិត្តទៅដល់សង្គមទាំងមូល។

## ប្រធានបទសំខាន់ៗរួមមានដូចតទៅ:

- ការយល់ដឹងពីសន្តិភាព ទំនាស់ និងអំពើហិង្សា
- ទ្រឹស្តី និងមូលហេតុទំនាស់
- ការវិភាគទំនាស់សំរាប់អ្នកសារព័ត៌មាន
- ប្រពន្ធ័ផ្សព្វផ្សាយ និងទំនាស់
- វិធីសាស្រ្តនានាដើម្បីដោះស្រាយទំនាស់

*កម្មវិធីសិក្សា*

វគ្គសិក្សា ទីមួយ : ថ្ងៃទី ០៣-០៧ ខែឧសភា ឆ្នាំ ២០១០ ( សំរាប់ប្រធាន ឬមន្រ្តីសមាគម និងក្លឹបអ្នកសារព័ត៌មាន)

វគ្គសិក្សា ទីពីរ : ថ្ងៃទី ២៦-៣០ ខែកក្កដា ឆ្នាំ ២០១០( សំរាប់ អ្នកសារព័ត៌មាន, ទូរទស្សន៍, វិទ្យុ, ទស្សនាវដ្តី)

## វគ្គសិក្សានេះបង្កើតឡើងសំរាប់នរណា?

អ្នកចូលរួមក្នុងវគ្គសិក្សានេះនឹងត្រូវជ្រើសរើសចេញមកពីស្ថាប័នសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយនានា។ វគ្គសិក្សានឹងផ្តល់អាទិភាពដល់អ្នកសារព័តិមាន អ្នកដឹកនាំក្លឹប សមាគមអ្នកសារព័តិមាន និងមន្ត្រីរដ្ឋាភិបាលដែលពាក់ពន្ធ័ផ្ទាល់នឹងការគាំទ្រសកម្មភាពអភិវឌ្ឍន៏ប្រពន្ធ័ផ្សព្វផ្សាយជាមួយនឹងអ្នកសារព័តិមានក្នុងស្រុក និងសមាគមសារត័តិមាន ជាពិសេសសំរាប់អ្នកកាសែត និពន្ធនាយក ចាងហ្វាង និងអ្នកសារព័តិមាន ដែលធ្វើការផ្ទាល់ជាមួយនឹងការផ្សព្វផ្សាយអំពីវប្បធមិសន្តិភាព និងការការពារទំនាស់នៅក្នុងសេវាសាធារណៈ ។

សូមជំរាបផងដែរថា វគ្គបណ្តុះបណ្តាលនេះ កំណត់ទទួលបេក្ខជនដែលមានលក្ខណៈសមស្របត្រឹមតែ ២៥នាក់ប៉ុណ្ណោះ ហើយបេក្ខជនទាំងនោះ ត្រូវតាំងចិត្តចូលរួមវគ្គសិក្ខាសាលាអោយបានពេញលេញ នឹងត្រូវបំពេញលក្ខខណ្ឌនានារបស់វគ្គសិក្សា។ ស្រ្តីត្រូវបានលើកទឹកចិត្តជាពិសេស ដើម្បីដាក់ពាក្យចូលរៀន។ រីឯកាលបរិច្ឆេទឈប់ទទួលពាក្យ នៅថ្ងៃ **ព្រហស្បតិ៍ ទី ១៥ ខែមេសា ឆ្នាំ២០១០**។

## គោលបំណងនៃវគ្គសិក្សា

វិធីសាស្រ្តបង្រៀន រចនាសម្ព័ន្ធ និងសកម្មភាពផ្សេងៗ ត្រូវបានប្រើក្នុងគោលបំណងអោយអ្នកចូលរួមអាចមើលឃើញនូវបញ្ហាផ្ទាល់របស់គេដែលទាក់ទិននឹងទំនុកចិត្តក្នុងការផ្សព្វផ្សាយព័តិមានជាសាធារណៈ និងការយល់ដឹងពីរបៀបនៃការសរសេរដែលអាចផ្សព្វផ្សាយព័តិមានដោយអាចជួយកាត់បន្ថយទំនាស់ និងកសាងការយល់ដឹងអំពីសន្តិភាពនៅក្នុងសង្គម។ វគ្គបណ្តុះបណ្តាលនេះក៏ជាឱកាសមួយផងដែរ ដើម្បីពិនិត្យមើលផលប៉ះពាល់នៃប្រពន្ធ័ផ្សព្វផ្សាយទៅលើទស្សនៈរបស់មហាជន និងរិះរកនូវគោលការណ៏ផ្សាយព័តិមានដោយសន្តិភាព និងការចូលរួមកសាងសន្តិភាព។ ជាពិសេសមានបំណងផ្តល់អោយអ្នកចូលរួមនូវការយល់ដឹង :

- មូលដ្ឋានផ្អែកទ្រឹស្តីដើម្បីយល់ដឹងនូវភាពស្មុគស្មាញនៃទំនាស់
- ឧបករណ៏សំរាប់ធ្វើការវិភាគលើការគ្រប់គ្រង និង អន្តរាគមន៏ទំនាស់
- ឱកាសសំរាប់ធ្វើការគិតពិចារណាទៅលើតួនាទីរបស់ពួកគេ ក្នុងការធ្វើអន្តរាគមន៏លើទំនាស់និងការកសាងសន្តិភាព
- មធ្យោបាយដើម្បីពិនិត្យឡើងវិញនូវជំនឿ ចរិត និង អាកប្បកិរិយា ដែលនាំទៅរកទំនាស់ ឬទៅរកសន្តិភាព
- ឱកាសដើម្បីរៀនអនុវត្តការធ្វើទំនាក់ទំនង និង ការធ្វើជំនាញក្នុងការសម្របសម្រួល
- ជំនាញដើម្បីធ្វើអន្តរាគមន៏ និងដោះស្រាយទំនាស់ប្រកបដោយការស្ថាបនា និងអហិង្សា

## វិធីសាស្រ្តនៃវគ្គសិក្សា

វិធីសាស្រ្តនៃវគ្គសិក្សានេះ គឺមានទំនាក់ទំនងគ្នាទៅវិញទៅមក ដោយលើកយកការសិក្សាយ៉ាងលំអិតនូវវិធីសាស្រ្តផ្សេងៗ ដូចជា : ការប្រមូលគំនិត សំដែងឈុត ការនិយាយរឿង ការពិភាក្សាក្រុម ធ្វើការជាដៃគូ បញ្ចាំងវីដេអូ ។ល។ វិធីសាស្រ្តសិក្សាសំរាប់វគ្គនេះ រួមមានបទបង្ហាញដែលនឹងត្រូវយកមកប្រើនៅក្នុងវគ្គសិក្សា ដើម្បីបង្កើតបរិយាកាសសិក្សារៀនសូត្រ។ អ្នកចូលរួមត្រូវគេរំពឹងថា នឹងរកមើល និងលើកយកករណីសិក្សាដោយផ្អែកលើបទពិសោធន៏ទំនាស់ផ្ទាល់របស់អ្នកសារព័តិមានដែលទាក់ទងនឹងសន្តិភាព និងទំនាស់ និងលក្ខណៈអាជីពរបស់ប្រពន្ធ័ផ្សព្វផ្សាយ ដើម្បីវាយតម្លៃប្រសិទ្ធភាពនៃគំរូ ទស្សនៈ និងទ្រឹស្តី ដែលបានណែនាំបង្ហាញ។

## មាតិកានៃវគ្គសិក្សា

ប្រធានបទសំខាន់ៗមានរៀបរាប់ដូចខាងក្រោម ប៉ុន្តែអាចផ្លាស់ប្តូរអាស្រ័យទៅលើតម្រូវការរបស់ក្រុមគោលដៅ។ ទោះបីជា មាតិកាអាចខុសគ្នាពីការរៀបរាប់ខាងក្រោមក្តី ក៏គោលគំនិតមូលដ្ឋាន ជំនាញ និងដំណើរការនៅទាក់ទងគ្នាដដែល។

កម្មវិធីសិក្សារួមមាន ៖

**ការយល់ដឹងពីសន្តិភាព**
-ទស្សនៈនៃសន្តិភាព
-សន្តិភាពអវិជ្ជមាន និងសន្តិភាពវិជ្ជមាន
-តើសន្តិភាពសំរាប់នរណា?

**ការយល់ដឹងពីទំនាស់**
-តើហេតុអ្វីត្រូវសិក្សាអំពីទំនាស់?
-តើទំនាស់ជាអ្វី?
-ស្ថានភាពទំនាស់ និងផលប៉ះពាល់

**ការយល់ដឹងពីអំពើហិង្សា**
-អំពើហិង្សាលើរាងកាយ និងអំពើហិង្សាជារចនាសម្ពន្ធ័
-វដ្តនៃអំពើហិង្សា

**ទ្រឹស្តី និងមូលហេតុទំនាស់**
-ទ្រឹស្តីនៃការបង្កទំនាស់
- សញ្ញាខន្ធ បុរេនិច្ឆ័យ ផ្នត់គំនិត និង ការរើសអើង

**ការវិភាគទំនាស់សំរាប់អ្នកសារព័ត៌មាន**
-តើអ្វីជាចំណុចគោលនៃការវិភាគ?
-ឧបករណ៍វិភាគ ៖ ការគូរផែនទីទំនាស់ ត្រីកោណ ប.ទ.ច. និងការវិភាគទំនាស់តាមដើមឈើ

**ប្រពន្ធ័ផ្សព្វផ្សាយ និងទំនាស់**
-អ្នកសារព័ត៌មានដែលយកចិត្តទុកដាក់នឹងទំនាស់
-តួនាទីនៃអ្នកសារព័ត៌មាននៅក្នុងស្ថានភាពទំនាស់
-ផលប៉ះពាល់នៃប្រពន្ធ័ផ្សព្វផ្សាយមកលើទស្សនមហាជន

**វិធីសាស្ត្រនានាដើម្បីដោះស្រាយទំនាស់**
-ជំនាញប្រាស្រ័យទាក់ទងដើម្បីការពារទំនាស់
-គោលការណ៍នៃការផ្សាយព័ត៌មានដែលមានលក្ខណៈវិជ្ជាជីវៈ
-ការចូលរួមចំណែករបស់អ្នកសារព័ត៌មានដើម្បីកសាងសន្តិភាព
-ជំនាញអន្តរាគមន៍ទំនាស់ ៖ ការចរចា និង ការសម្រុះសម្រួល

## ពាក្យសុំចូលរៀន

អ្នកមានបំណងដាក់ពាក្យសុំចូលរៀន អាចបំពេញបែបបទដែលបានផ្តល់ជូន និងដាក់មកវិទ្យាស្ថាន CDRI ឬទាក់ទងមកលោកស្រី **ហ៊ុយ រំដួល** មន្ត្រីកម្មវិធីជាន់ខ្ពស់។
វគ្គសិក្សាពី *តួនាទីអ្នកសារព័ត៌មានដើម្បីកសាងសន្តិភាព* មិនតំរូវអោយបង់ថ្លៃសិក្សាទេ អ្នកចូលរួមទាំងអស់ដែលបានជ្រើសរើសអោយចូលរួមវគ្គសិក្សានេះតំរូវអោយចូលរួមសិក្សានៅក្នុងវគ្គអោយបានពេញលេញ។

កាលបរិច្ឆេទឈប់ទទួលពាក្យគឺ **ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១០**។ សំរាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងលោកស្រី ហួន ចន្ទ្រា ទូរសព្ទ័ លេខ ០២៣ ៨៨១ ៣៨៤។

សំរាប់ព័ត៌មានបន្ថែម សូមមើល www.cdri.org.kh ឬទំនាក់ទំនងជាមួយលោកស្រី ហ៊ុយ រំដួល ឬលោកស្រី ហួន ចន្ទ្រា ។

កម្មវិធីបណ្តុះបណ្តាលការកសាងសន្តិភាព
តាមអាសយដ្ឋាន: CDRI ផ្ទះលេខ៥៦ ផ្លូវលេខ៣១៥ សង្កាត់បឹងកក់១ ទួលគោក ភ្នំពេញ
ប្រអប់សំបុត្រ ៦២២ ភ្នំពេញ ឬ CCC Box 18
ទូរស័ព្ទលេខ ០២៣ ៨៨១ ៩១៦
ឬតាមរយៈ email: romduol@cdri.forum.org.kh ឬ chantrea@cdri.forum.org.kh